**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
រដ្ឋបាលជលផល

# សៀវភៅមេរៀនស្តីពី សហគ្រប់គ្រងធនធានជលផល

## សៀវភៅទី២ : ការពង្រឹងសហគមន៍នេសាទ



ខែសីហា ឆ្នាំ២០១៨

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សៀវភៅមេរៀនស្តីពីសហគ្រប់គ្រងធនធានជលផល

## សៀវភៅទី២ : ការពង្រឹងសហគមន៍នេសាទ


រៀបចំដោយ

វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍជលផលទឹកសាប

រដ្ឋបាលជលផល

**សេចក្ដីថ្លែងអំណរគុណ**

រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចងក្រងសៀវភៅមេរៀននេះ ក្រោមការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងធនាគារពិភពលោក។
សៀវភៅមេរៀនទាំងនេះគឺជាសមិទ្ធិផលរបស់គម្រោងការគ្រប់គ្រងធនធានទឹកចម្រុះ ទន្លេមេគង្គ - ដំណាក់កាលទី ៣ (M-IWRMP-III) "ការគាំទ្រការគ្រប់គ្រងធនធានជលផលនៅភូមិភាគឦសាននៃប្រទេសកម្ពុជា" ដែលអនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប។

**ចងក្រងដោយ**

រូបឺត៍ ផមរ៉យ អេរិក បារ៉ាន ទូច គឹមឆាន សូខន សារុទ្ធ លី វុទ្ធី ទុយ សមវាំ ឈួន ឡា
សូ រ័ត្នថាវី ផា ស្រួយ ប៊ុន ប៉ាស៊ី ទូច ប៊ុនថង ឆេង ផែន និង អេង ជាសាន។

**ជំនួយការ**

ស៊ឹម ថាវរី អ៊ូ សារី ជៀង សីហា ភូ សុខ ទិត្យ ពុទ្ធារ័ត្ន ប៉ុស ចាន់ណារ៉ា
កែន ឡៃហ៊ាង ភាជន៍ ឧស្សាហ៍ ទឹម សណ្ដាន និងគូររូបដោយ ហេង សន្ធា។
សូមថ្លែងអំណរគុណដល់អ្នកជំនាញការ និងទីប្រឹក្សានៃធនាគារពិភពលោកដែលបានផ្ដល់នូវមតិ និងកែលម្អ។

**ISBN-13: 978-9924-9278-3-9**

**គុណកថាបង្អែក**

រដ្ឋបាលជលផល (២០១៨). សៀវភៅបណ្ដុះបណ្ដាលស្ដីពីការសហការគ្រប់គ្រងជលផល សៀវភៅទី២៖ ការពង្រឹងសហគមន៍នេសាទ។ រដ្ឋបាលជលផល និងវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍ជលផលទឹកសាប រាជធានីភ្នំពេញ ប្រទេសកម្ពុជា ២៤ទំព័រ។

**អាសយដ្ឋានទំនាក់ទំនង**

រដ្ឋបាលជលផល
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប
អាគារលេខ ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា
គេហទំព័រ ifredi-cambodia.org

**© រដ្ឋបាលជលផល (២០១៨)**

រក្សាសិទ្ធិ។ ការបោះពុម្ពឡើងវិញទាំងស្រុង ឬផ្នែកណាមួយសម្រាប់គោលបំណងអប់រំ ឬមិនរកប្រាក់ចំណេញ ដោយមិនចាំបាច់សុំការអនុញ្ញាតពីម្ចាស់ដើម និងគ្រាន់តែថ្លែងអំណរគុណដល់ប្រភពដើមត្រូវបានអនុញ្ញាត។ រាល់ការបោះពុម្ពការចម្លង ឬចែកចាយសម្រាប់ធ្វើពាណិជ្ជកម្មត្រូវសុំការអនុញ្ញាតពីរដ្ឋបាលជលផល។
គ្រប់មតិ និងគំនិតទាំងអស់ជាទស្សនៈរបស់អ្នកនិពន្ធ និងមិនឆ្លុះបញ្ចាំងពីរដ្ឋបាលជលផល ដៃគូ ស្ថាប័នគាំទ្រគម្រោង និងការបោះពុម្ពសៀវភៅនេះ។

# មាតិកា


១. តើសហគ្រប់គ្រងសហគមន៍នេសាទមានន័យដូចម្តេច? ..................................................... ១
២. តួនាទី និងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋ នៅក្នុងសហគមន៍នេសាទ............................. ២
៣. គោលការណ៍គ្រប់គ្រងធនធានជលផលផ្តោតលើប្រព័ន្ធអេកូឡូស៊ី ........................................ ៤
៤. ការដោះស្រាយវិវាទ ........................................................................................ ៦
៥. កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍.................................................................. ៧
៦. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ............................................................. ៩
៦.១ មាតិកាផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍.....................................................១០
៦.១.១ សំណួរនានាទាក់ទងនឹងការរៀបចំផែនការគ្រប់គ្រង............................................ ១០
៦.១.២ សកម្មភាពយេនឌ័រក្នុងផែនការគ្រប់គ្រង.......................................................... ១១
៦.២ ដំណើរការ នៃការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ................................ ១២
៦.២.១ កំណត់ និងចាត់អាទិភាពបញ្ហា និងគោលបំណង.................................................. ១២
៦.២.២ ការបង្កើតផែនការគ្រប់គ្រង ........................................................................ ១៧
៦.២.៣ ការអនុវត្តផែនការគ្រប់គ្រង ........................................................................ ១៩
៧. ការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀង..............................................២២
៨. និរន្តរភាពសហគមន៍នេសាទ ...............................................................................២៣

## ១. តើសហគ្រប់គ្រងសហគមន៍នេសាទមានន័យដូចម្តេច?

**សហគ្រប់គ្រង** សំដៅដល់ភាពជាដៃគូរវាងសហគមន៍នេសាទ ស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធដទៃទៀត (ដូចជា៖ អ្នកលក់ត្រី អ្នកជំនួញ អង្គការមិនមែនរដ្ឋាភិបាល ។ល។) និងការបែងចែកសិទ្ធិរួមទាំងការទទួលខុសត្រូវក្នុងការគ្រប់គ្រងធនធានជលផល។

សហគមន៍នេសាទនៅប្រទេសកម្ពុជា គឺអនុវត្តតាមគោលការណ៍សហគ្រប់គ្រង។ ស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាលគឺជាដៃគូជាមួយនឹងសហគមន៍នេសាទក្នុងការគ្រប់គ្រងធនធានជលផល។

តាមរយៈកិច្ចពិគ្រោះយោបល់ និងការចរចា រដ្ឋបាលជលផល និងសហគមន៍នេសាទត្រូវបង្កើតកិច្ចព្រមព្រៀងដូចជា៖ កន្លែងនេសាទសហគមន៍ តួនាទី និងភារកិច្ចរបស់ភាគីពាក់ព័ន្ធ និងសិទ្ធិក្នុងការគ្រប់គ្រងធនធានជលផល។

សហគ្រប់គ្រងធនធានជលផលរួមមាន៖

- សមាជិកភាពប្រកបដោយសមធម៌៖ យុត្តិធម៌ ស្មើភាព និងបើកទូលាយចំពោះប្រជាពលរដ្ឋទូទៅ (ស្ត្រី និងជនជាតិដើមភាគតិចត្រូវបានលើកទឹកចិត្តឱ្យចូលជាសមាជិកសហគមន៍នេសាទ)
- រួបរួមគ្នា និងសហប្រតិបត្តិការ៖ ធ្វើការជាមួយអ្នកណាម្នាក់ ផលិតអ្វីមួយ
- បែងចែកសិទ្ធិអំណាច (ការទទួលខុសត្រូវ និងសិទ្ធិអំណាច)៖ ទទួលខុសត្រូវរួមគ្នាលើការសម្រេចចិត្ត
- មានគោលដៅច្បាស់លាស់
- កិច្ចព្រមព្រៀង៖ ការរៀបចំរវាងភាគីពាក់ព័ន្ធ ចំពោះសកម្មភាពជាក់លាក់។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

វិធីសាស្ត្រនៃការគ្រប់គ្រងធនធានជលផល គឺការទទួលស្គាល់នូវការចូលរួមពីប្រជានេសាទ ការទទួលស្គាល់ភាពជាម្ចាស់ និងសម្រេចចិត្តរួមគ្នា។

កាលពីមុន ការសម្រេចចិត្តនានាទាក់ទងនឹងការគ្រប់គ្រងធនធានជលផល មានលក្ខណៈប្រមូលផ្តុំ និងស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល (រដ្ឋបាលជលផលធ្វើការសម្រេចចិត្ត អនុវត្តសកម្មភាព ត្រួតពិនិត្យការងារ និងដាក់ពិន័យជាដើម)។ ចំពោះសហគ្រប់គ្រងធនធានជលផលវិញ ការសម្រេចចិត្តលើការគ្រប់គ្រងធនធានជលផល និងការទទួលខុសត្រូវ ត្រូវបានបែងចែករវាងសហគមន៍នេសាទ និងស្ថាប័នរាជរដ្ឋាភិបាល។

## ២. តួនាទី និងការទទួលខុសត្រូវរបស់ប្រជាពលរដ្ឋ នៅក្នុងសហគមន៍នេសាទ

សមាជិកនៃសហគមន៍នេសាទនីមួយៗ មានសិទ្ធិ៖

- ចូលរួមប្រជុំបោះឆ្នោត និងឈរឈ្មោះឱ្យគេបោះឆ្នោតក្នុងគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានកិច្ចប្រជុំ និងលើកឡើងនូវបញ្ហាទាក់ទងនឹងជលផល និងពិភាក្សារកដំណោះស្រាយ
- នេសាទជាលក្ខណៈគ្រួសារ ដោយគោរពតាមច្បាប់ និងលិខិតបទដ្ឋានដែលទាក់ទងទៅនឹងវិស័យជលផល លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ
- ចូលរួមគ្រប់សកម្មភាពរបស់សហគមន៍នេសាទ
- តវ៉ាចំពោះបញ្ហាទាំងឡាយដែលប៉ះពាល់ដល់ផលប្រយោជន៍សហគមន៍នេសាទ ទៅក្រុមប្រឹក្សា ឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន រដ្ឋបាលជលផល និងសមត្ថកិច្ចពាក់ព័ន្ធនានា។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ប្រជានេសាទណាម្នាក់ចង់ចូលជាសមាជិកសហគមន៍នេសាទ ត្រូវតែបង្ហាញឆន្ទៈគោរពតាមប្រការនានានៃអនុក្រឹត្យស្តីពីសហគមន៍នេសាទ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងគោរពរាល់ការសម្រេចទាំងឡាយ ដែលអនុម័តដោយមហាសន្និបាតរបស់សហគមន៍។

ក្នុងករណី សមាជិកនៃសហគមន៍នេសាទណាម្នាក់រារាំងមិនឱ្យសមាជិកដទៃទៀតក្នុងសហគមន៍ ដែលអនុវត្តសិទ្ធិ ឬធ្វើឱ្យមានការប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍សហគមន៍ ឬសមាជិកសហគមន៍នេសាទដទៃទៀត សមាជិករូបនោះត្រូវព្យួរ ឬបណ្តេញចេញពីសហគមន៍ ក្រោយពីបានការពារខ្លួននៅចំពោះមុខគណៈកម្មការសហគមន៍នេសាទ។

គណៈកម្មការសហគមន៍នេសាទ មានភារកិច្ចៈ

- រៀបចំ និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- រៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ទទួលបានការឯកភាពពីខណ្ឌរដ្ឋបាលជលផល និងរដ្ឋបាលជលផលថ្នាក់កណ្តាល លើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- គ្រប់គ្រងការអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ពិនិត្យឡើងវិញនូវផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជាមួយនឹងខណ្ឌរដ្ឋបាលជលផល
- រៀបចំរបាយការណ៍ប្រចាំត្រីមាស និងដាក់ជូនខណ្ឌរដ្ឋបាលជលផល និងរាយការណ៍អំពីការបំពានច្បាប់នានា
- ដោះស្រាយវិវាទដែលមានក្នុងសហគមន៍នេសាទ
- បើកគណនីធនាគារ និងគ្រប់គ្រងហិរញ្ញវត្ថុរបស់សហគមន៍
- រៀបចុះកិច្ចប្រជុំ និងពិគ្រោះយោបល់ជាមួយសមាជិកសហគមន៍
- ធ្វើការសម្រេចចិត្ត ដោយឈរលើការឯកភាពពីសមាជិកភាគច្រើន។

## ៣. គោលការណ៍គ្រប់គ្រងធនធានជលផលផ្តោតលើប្រព័ន្ធអេកូឡូស៊ី

**វិធីសាស្រ្តគ្រប់គ្រងដោយផ្តោតលើប្រព័ន្ធអេកូឡូស៊ី** គឺជាវិធីសាស្រ្តមួយដែលមានតុល្យភាពរវាងសមាសធាតុចំនួនបី គឺបរិស្ថាន សង្គម( សុខុមាលភាព) និងអភិបាលកិច្ច។

- បរិស្ថានល្អ៖ មានពូជត្រីច្រើនប្រភេទ ផលត្រីសម្បូរ មិនធ្វើឱ្យខូចខាតជម្រកត្រី និងទឹកមានគុណភាព
- សង្គម( សុខុមាលភាព)៖ ប្រជាពលរដ្ឋមានស្តង់ដាររស់នៅល្អ (ប្រាក់ចំណូលសមរម្យ) សុវត្ថិភាពស្បៀង ទំនាក់ទំនងសង្គមមានភាពប្រសើរឡើង និងធានាសុវត្ថិភាព
- អភិបាលកិច្ចល្អ៖ សំដៅដល់ការចូលរួម សិទ្ធិជាផ្លូវការ សមធម៌ យន្តការរៀបចំផែនការ និងការអនុវត្ត ការគោរព និងពង្រឹងការអនុវត្តន៍ច្បាប់។

វាជាវិធីសាស្រ្តដែលគិតគូរទៅលើជាតុសំខាន់ៗនៅក្នុងប្រព័ន្ធអេកូឡូស៊ី ហើយគិតគូរពីផលប្រយោជន៍សេដ្ឋកិច្ចសង្គមបានមកតាមរយៈការប្រើប្រាស់ធនធានប្រកបដោយនិរន្តរភាព។




### គន្លឹះសម្រាប់អ្នកសម្របសម្រួល

ត្រីរស់នៅបានអាស្រ័យនឹងប្រព័ន្ធអេកូឡូស៊ី (រួមមានកត្តាទឹក ជម្រកពងកូន និងមនុស្ស)។ ការគ្រប់គ្រងធនធានជលផល ដោយមិនបានគ្រប់គ្រងបរិស្ថាននាំឱ្យគ្មានប្រសិទ្ធភាព និងគ្មាននិរន្តរភាព។ នៅពេលខ្លះ ការគ្រប់គ្រងធនធានជលផលខកខានក្នុងការការពារសហគមន៍ក្រីក្រ ដែលតែងតែទាញ

ផលប្រយោជន៍ពីធនធានធម្មជាតិ ក៏ដូចជាផលប្រយោជន៍សេដ្ឋកិច្ចសង្គម។ ដើម្បីឆ្លើយតបនឹងតម្រូវការនេះ "ការគ្រប់គ្រងធនធានជលផលតាមបែបប្រព័ន្ធអេកូឡូស៊ី" ត្រូវបានបង្កើតឡើង។ វិធីសាស្ត្រនេះមានលក្ខណៈចូលរួម និងចម្រុះ ដែលពិចារណាផ្តោតលើ៖ ១)ធនធានជលផល ២)ជាតុសំខាន់ៗនៃប្រព័ន្ធអេកូឡូស៊ី និង ៣)ផលប្រយោជន៍សេដ្ឋកិច្ចសង្គមដែល
ទទួលបាន។

ការគ្រប់គ្រងធនធានជលផលដែលកំពុងដំណើរការមិនទាន់ឆ្លើយតបទៅលើការគំរាមកំហែង និងបញ្ហាទាំងអស់ដែលប្រឈមនឹងការនេសាទបានទេ (ដូចជាការបាត់បង់ទីជម្រក និងមិនមានសមធម៌) នឹងអាចបរាជ័យថែមទៀតផង។ វិធីសាស្ត្រមានលក្ខណៈទូលំទូលាយ និងមានការរួមបញ្ចូលច្រើនជាងនេះ ត្រូវបានប្រើប្រាស់ជាចាំបាច់ នោះគឺការគ្រប់គ្រងធនធានជលផលផ្តោតលើប្រព័ន្ធអេកូឡូស៊ី៖

- វិធីសាស្ត្រគ្រប់គ្រងដោយមានលក្ខណៈគ្រប់ជ្រុងជ្រោយ រួមបញ្ចូល និងមានការចូលរួមដែលគិតគូរអំពីសមាសជាតុសំខាន់ៗនៅក្នុងប្រព័ន្ធអេកូឡូស៊ី និងអត្ថប្រយោជន៍សង្គម និងសេដ្ឋកិច្ចដែលអាចទាញយកតាមរយៈការប្រើប្រាស់ប្រកបដោយនិរន្តរភាព
- ធ្វើឱ្យមានតុល្យភាពរវាង សុខុមាលភាពបរិស្ថាន និងសុខុមាលភាពរបស់មនុស្ស តាមរយៈអភិបាលកិច្ចល្អសំរាប់មនុស្សជំនាន់ក្រោយ
- ផ្តល់នូវទស្សនៈវិស័យមួយដែលមិនត្រឹមតែជាការនេសាទប៉ុណ្ណោះទេ វាក៏រួមបញ្ចូលទាំងបរិស្ថានល្អ និងទីជម្រក ព្រមទាំងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនផងដែរ
- ត្រូវបានទទួលស្គាល់ថាត្រី និងធនធានជលផលដទៃទៀត គឺជាផ្នែកមួយនៃប្រព័ន្ធអេកូឡូស៊ីដែលមានលក្ខណៈទូលំទូលាយដែលរួមបញ្ចូលជម្រកត្រីរស់នៅ ក៏ដូចជាប្រជាពលរដ្ឋដែលទទួលបានផលប្រយោជន៍ពីការនេសាទ លក់ដូរ និងការបរិភោគត្រី។

**វិធីសាស្ត្រគ្រប់គ្រងដោយមានភាពទន់ភ្លន់៖**

វិធីសាស្ត្រនេះសំដៅដល់ការត្រួតពិនិត្យនិងវាយតម្លៃវិធានការគ្រប់គ្រងសរុបដោយប្រៀបធៀបជាមួយនឹងយុទ្ធសាស្ត្រដែលបានអនុវត្តកន្លងមក ឬយុទ្ធសាស្ត្រ ដែលបានអនុវត្តកន្លងមកដោយសហគមន៍ដទៃទៀត។ យុទ្ធសាស្ត្រត្រូវកែលម្អដោយឈរលើមេរៀននិងបទពិសោធន៍កន្លងមក។

**វិធីសាស្ត្រគ្រប់គ្រងតាមបែបបង្ការជាមុន៖**

វិធីសាស្ត្រនេះសំដៅដល់ការគិតគូរទុកជាមុន។ ឧទា. បើសិនជាសហគមន៍នេសាទអាច

អនុញ្ញាតឱ្យដាក់លាន់អន្ទង់ចំនួន១០០យ៉ាងច្រើន និងតិចបំផុត៧០។ សហគមន៍អាចឱ្យដាក់ត្រឹមតែចំនួន ៧០លាន់អន្ទង់សិន។ បើសិនជាគេមានទិន្នន័យបង្ហាញកំណើនធនធានជលផល មានន័យថាផលស្តុកត្រីក៏មានកំណើនដែរ ពេលនោះសហគមន៍អាចអនុញ្ញាតបង្កើនចំនួនឧបករណ៍បន្ថែមទៀត។

## ៤. ការដោះស្រាយវិវាទ

នៅក្នុងផែនការគ្រប់គ្រងត្រូវគិតគូរអំពីការដោះស្រាយវិវាទ៖

- វិវាទក្នុងសហគមន៍នេសាទ
- វិវាទរវាងសមាជិកសហគមន៍នេសាទ និងប្រជាពលរដ្ឋ
- វិវាទរវាងសហគមន៍នេសាទនិងអ្នកមកពីខាងក្រៅ។

យន្តការដោះស្រាយវិវាទ គួររួមបញ្ចូលនូវ៖

- ការដោះស្រាយវិវាទដំបូងៗ (ពេលដែលភាគីទាំងអស់ត្រៀមនឹងដោះស្រាយ)
- វិវាទធំៗ (ពេលដែលភាគីទាំងអស់ទំនងជាមិនឯកភាពគ្នា)។

ក្នុងករណីនីមួយៗ គួរបញ្ចូលនូវ៖

- អ្នកណា ជាអ្នកជួយដោះស្រាយ
- អ្នកណា ជាអ្នកសម្រេច ក្នុងករណីដែលមិនមានការឯកភាពគ្នា។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ (ជំពូកទី ១១ ប្រការ ៣៣) ចែងថា វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទត្រូវបានដោះស្រាយដូចខាងក្រោម៖

- គណៈកម្មការសហគមន៍នេសាទត្រូវសម្របសម្រួល និងដោះស្រាយរាល់វិវាទ ដែលកើតឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន
- ក្នុងករណី គណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទពុំបានសម្រេច ត្រូវតែបញ្ជូនសំណុំរឿងនោះទៅរដ្ឋបាលជលផលដើម្បីដោះស្រាយឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងមន្ត្រីពាក់ព័ន្ធតាមការចាំបាច់
- ក្នុងករណីដែលវិវាទនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និងរដ្ឋបាលជលផលត្រូវតែបញ្ជូនសំណុំរឿងទៅតុលាការខេត្ត ក្រុងសាមី ដើម្បីដោះស្រាយតាមច្បាប់ "។

ការបង្កើតយន្តការដោះស្រាយវិវាទពីដំណាក់កាលដំបូង នៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ នឹងជួយកសាងទំនុកចិត្ត និងចៀសវាងវិវាទដែលនឹងត្រូវចំណាយពេលវេលា ថវិកាក្នុងដំណើរការអនុវត្តផែនការ។ សហគមន៍នេសាទដែលរួមបញ្ចូលយន្តការគ្រប់គ្រងវិវាទទំនងជាទទួលបានជោគជ័យច្រើន ក្នុងការសម្រេចគោលបំណងនៃការគ្រប់គ្រង គោលដៅបរិស្ថាន និងសង្គម ជាជាងសហគមន៍នេសាទដែលមិនមានយន្តការគ្រប់គ្រងវិវាទ។

## ៥. កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

**កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍** រវាងសហគមន៍នេសាទ និងរដ្ឋបាលជលផល ទទួលស្គាល់ និងជានាសិទ្ធិរបស់សហគមន៍នេសាទ ចំពោះផែនទីដែលបានកំណត់។

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ គួរបញ្ចូលចំណុចសំខាន់ៗ៖

- ភាគីហត្ថលេខី និងតួនាទី និងការទទួលខុសត្រូវរបស់ភាគីនីមួយៗ
- ទីកន្លែង និងទំហំដែននេសាទ
- លក្ខខណ្ឌ និងពេលវេលានៃការគ្រប់គ្រង និងការប្រើប្រាស់ឧបករណ៍នេសាទ
- លក្ខខណ្ឌនៃវិសោធនកម្ម និងការបញ្ចប់កិច្ចព្រមព្រៀង។



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ គឺជាកិច្ចព្រមព្រៀងតាមលក្ខណៈច្បាប់ ដោយរដ្ឋបាលជលផល ក្នុងការផ្ទេរដែននេសាទទៅឱ្យសហគមន៍នេសាទគ្រប់គ្រងប្រកបដោយនិរន្តរភាពក្នុងរយៈពេល៣ឆ្នាំ។ នៅក្នុងកិច្ចព្រមព្រៀងមានបញ្ជាក់ពីឧបករណ៍នេសាទ តួនាទីរបស់ខណ្ឌរដ្ឋបាលជលផលក្នុងការគាំទ្រសហគមន៍នេសាទ និងនីតិវិធីរាយការណ៍អំពីការបំពាននានា។

ដើម្បីឱ្យកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍មានសុពលភាពត្រូវមានភាគីពីរចុះហត្ថលេខា គឺនាយខណ្ឌរដ្ឋបាលជលផល និងគណៈកម្មការសហគមន៍នេសាទ និងហត្ថលេខារបស់របស់មេឃុំចៅសង្កាត់ ក្នុងនាមជាសាក្សី។

នៅក្នុងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ មានចែងច្បាស់អំពី៖

- តួនាទី និងការទទួលខុសត្រូវរបស់ភាគីនីមួយៗ
- ទីកន្លែង និងទំហំដែននេសាទ
- លក្ខខណ្ឌ និងពេលវេលានៃការគ្រប់គ្រង និងការប្រើប្រាស់ឧបករណ៍នេសាទ
- លក្ខខណ្ឌនៃវិសោធនកម្ម និងការបញ្ចប់កិច្ចព្រមព្រៀង។

យោងតាមប្រកាស ស្ដីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទជំពូកទី៨ ប្រការ២១ចែងថា៖ ឯកសារនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រូវមានភ្ជាប់ជាមួយនូវ៖

- ផែនទី (មាត្រដ្ឋាន ១/៥០០០០) បង្ហាញពីទំហំកន្លែងនេសាទសហគមន៍ ដោយមានប្រព័ន្ធកូអ័រដោនេ(អាប់ស៊ីស និងអ័រដោនេ) ច្បាស់លាស់

- បញ្ជីឈ្មោះសមាជិកសហគមន៍ និងគណៈកម្មការសហគមន៍នេសាទ
- ឯកសារលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង
- លិខិតបញ្ជាក់ពីគោលបំណងបង្កើតសហគមន៍នេសាទ និងការគ្រប់គ្រងធនធានជលផល

គណៈកម្មការសហគមន៍នេសាទត្រូវបិទផ្សាយកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ នៅទីសាធារណៈដែលងាយស្រួលអាន នៅឃុំសង្កាត់ ក្រុងស្រុក និងរាជធានីខេត្ត រយៈពេល ៣០ថ្ងៃ មុននឹងដាក់ជូនរដ្ឋបាលជលផលដើម្បីពិនិត្យ និងឯកភាព។

## ៦. ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

គោលបំណងនៃការរៀបចំផែនការគ្រប់គ្រងគឺកំណត់នូវ៖

- គោលដៅ គោលបំណង យុទ្ធសាស្ត្រ និងសកម្មភាព
- តួនាទី និងភារកិច្ចរបស់សមាជិកសហគមន៍នេសាទ និងស្ថាប័នជំនាញរបស់រាជរដ្ឋាភិបាល

នៅក្នុងផែនការគួរបញ្ចូល៖

- បញ្ហាបរិស្ថាន៖ (ឧទា. ផលប៉ះពាល់លើជម្រកពងកូន កូនត្រីតូចៗ)
- បញ្ហាសង្គម (ឧទា. វិវាទ សុខភាព សុវត្ថិភាព និងការកែច្នៃផលនេសាទ)
- បញ្ហាអភិបាលកិច្ច៖ (ឧទា. ដំណើរការពិគ្រោះយោបល់ និងការចូលរួមរបស់ស្ត្រី)



### គន្លឹះសម្រាប់អ្នកសម្របសម្រួល

ទោះជាសមាជិកសហគមន៍នេសាទភាគច្រើនធ្លាប់មានបទពិសោធន៍ជាមួយនឹងការរៀបចំ និងការអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រួចហើយក៏យើងបានស្នើសុំឱ្យមានការធ្វើបច្ចុប្បន្នភាព និងការបំពេញបន្ថែមមួយចំនួន ដើម្បីរួមបញ្ចូលគោលការណ៍ និងព័ត៌មានលម្អិតជាក់ស្តែងខ្លះៗនៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

## ៦.១ មាតិកាផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ៦.១.១ សំណួរនានាទាក់ទងនឹងការរៀបចំផែនការគ្រប់គ្រង

ខ្លឹមសារមានក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ គួរឆ្លើយនឹងសំណួរខាងក្រោម៖

- តើមានគោលដៅ និងគោលបំណងអ្វីខ្លះ ដែលចង់សម្រេចឱ្យបាន?
- តើមានសកម្មភាពចម្បងៗអ្វីខ្លះ ដើម្បីសម្រេចគោលដៅ និងគោលបំណង?
- តើសង្ឃឹមថានឹងទទួលបានលទ្ធផលអ្វីខ្លះ?
- តើត្រូវការរយៈពេលប៉ុន្មាន ក្នុងការអនុវត្តយុទ្ធសាស្ត្រនេះ?
- តើអ្នកណាខ្លះជាអ្នកអនុវត្តសកម្មភាព?
- តើអ្នកណាជាអ្នកទទួលខុសត្រូវអនុវត្តសកម្មភាព?
- តើមានតម្រូវការហិរញ្ញវត្ថុប៉ុន្មាន និងមានប្រភពមកពីណា?



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

នៅក្នុងឧបសម្ព័ន្ធទី៤នៃ ប្រកាសស្ដីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទបានបង្ហាញពីគំរូនៃការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ។ វាជាគំរូទូទៅមួយ ដែលសហគមន៍នេសាទត្រូវបំពេញព័ត៌មានដែលមានស្រាប់ត្រង់ចន្លោះទំនេរ។ ទម្រង់នោះ ដូចជាមិនបានផ្ដល់ការណែនាំជាក់លាក់សម្រាប់ការរៀបចំទេ។ ហេតុនេះក្រុមបច្ចេកទេសផ្ដល់បន្ថែមនូវគោលការណ៍ជាក់ស្ដែងសម្រាប់រៀបចំ។

## ៦.១.២ សកម្មភាពយេនឌ័រក្នុងផែនការគ្រប់គ្រង

ទិដ្ឋភាព និងសកម្មភាពដែលទាក់ទងនឹងយេនឌ័រ គួរត្រូវបានបញ្ចូលក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍មានដូចជា៖

- គោលដៅ និងគោលបំណងដែលឆ្លើយតបនឹងតម្រូវការរបស់បុរស និងស្ត្រី
- ការវិនិយោគលើការកែលម្អបច្ចេកទេសកែច្នៃផលនេសាទដែលក្រុមស្ត្រីត្រូវការ
- សកម្មភាពនានា សំដៅលើកកម្ពស់ការចូលរួមរបស់ស្ត្រី ក្នុងគណៈកម្មការសហគមន៍នេសាទ
- ការបណ្ដុះបណ្ដាលដែលលើកកម្ពស់សមធម៌ និងសមភាពស្ត្រី ក្នុងវិស័យវារីវប្បកម្ម និងជលផល

កិច្ចប្រជុំជាមួយក្រុមស្ត្រីគួរត្រូវបានរៀបចំដោយឡែក ដើម្បីកំណត់បញ្ហាតម្រូវការ និងឱកាសរបស់ស្ត្រី រួចមកបញ្ចូលបញ្ហា តម្រូវការ និងឱកាសទាំងនោះទៅក្នុងផែនការគ្រប់គ្រង។



## ៦.២ ដំណើរការ នៃការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

### ៦.២.១ ការកំណត់ និងចាត់អាទិភាពបញ្ហា និងគោលបំណង

#### ៦.២.១.១ ការកំណត់បញ្ហា និងការគំរាមកំហែង

ការកំណត់បញ្ហា និងការគំរាមកំហែងទាក់ទងនឹងវិស័យជលផល ។ បញ្ហា និងការគំរាមកំហែងរួមមាន៖

- បរិស្ថាន៖ សំដៅលើកិច្ចការពារ និងស្តារជម្រកត្រី កាត់បន្ថយការបំពុលទឹក ការគ្រប់គ្រងកាកសំណល់ និងធនធានជលផល
- សង្គម៖ សំដៅលើសុវត្ថិភាពស្បៀង ការចិញ្ចឹមជីវិតដែលមាននិរន្តរភាព និងហេដ្ឋារចនាសម្ព័ន្ធជនបទ
- អភិបាលកិច្ច៖ សំដៅលើការចូលរួម ការផ្តល់អំណាច និងពង្រឹងស្ថាប័នជាដើម។

ការកំណត់បញ្ហាមិនគ្រាន់តែពិនិត្យលើវិស័យជលផលប៉ុណ្ណោះទេ តែត្រូវពិនិត្យទៅលើការអភិវឌ្ឍសហគមន៍ របរចិញ្ចឹមជីវិត សុវត្ថិភាពស្បៀង អភិបាលកិច្ច សេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថានថែមទៀត។



**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

នៅពេលសហគមន៍នេសាទបានចុះបញ្ជី សហគមន៍នោះពិតមានផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រួចជាស្រេច។ ដោយឡែក ជំហាននានានៃការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ (ការសិក្សាលទ្ធភាពបង្កើតសហគមន៍ ការផ្សព្វផ្សាយបំផុសសមាជិកសហគមន៍នេសាទ ការកំណត់ព្រំប្រទល់ និងធ្វើផែនទីកន្លែងនេសាទសហគមន៍) ត្រូវបានធ្វើរួចរាល់ មុននឹងបង្កើតសហគមន៍នេសាទ។ ក្រុមបច្ចេកទេសពិនិត្យឡើងវិញ និងបរិយាយលម្អិតអំពីចំណុចនានា នៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ល្អគួរបញ្ចូល និងមានប្រយោជន៍សម្រាប់សហគមន៍ដែលមិនទាន់មានផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ ឧទា.បញ្ហាជារួម៖ ត្រីថយចុះ

- បញ្ហាបរិស្ថាន៖ ត្រីថយចុះក្នុងដែននេសាទ ព្រោះមិនមានជម្រកពងកូន
- បញ្ហាសង្គម៖ ត្រីកាន់តិចទៅបណ្តាលឱ្យចំណូលធ្លាក់ចុះ
- បញ្ហាអភិបាលកិច្ច៖ គ្មានជំនួយពីខាងក្រៅ។

### ៦.២.១.២ ការចាត់អាទិភាពបញ្ហា ឬការតំរាមតំហែង

បន្ទាប់កំណត់បញ្ហាត្រូវចាត់អាទិភាពបញ្ហា មានន័យថាជ្រើសរើសចំនួនសកម្មភាពសំខាន់ៗ រួចកំណត់សកម្មភាពដែលសំខាន់ជាងគេ និងសកម្មភាពបន្តបន្ទាប់។ល។ ការងារនេះកំណត់អាទិភាពបញ្ហាដែលមានទំនាក់ទំនងជាមួយនឹងសកម្មភាព។



### ៦.២.១.៣ ការកំណត់តម្រូវការ និងចាត់អាទិភាព

គណៈកម្មការសហគមន៍នេសាទត្រូវសម្របសម្រួលជាមួយសមាជិក ក្នុងការកំណត់តម្រូវការ និងចាត់អាទិភាព ដែលឆ្លើយតបនឹងបញ្ហា និងការគំរាមកំហែងដែលរកឃើញខាងលើ។ នេះជាផ្នែកមួយសំខាន់ពីព្រោះវានឹងកំណត់នូវសកម្មភាពចម្បងៗដែលឆ្លើយតបនឹងតម្រូវការ។

ការកំណត់តម្រូវការ ដែលទាក់ទងជាមួយបញ្ហា និងការគំរាមកំហែង៖

បញ្ជីតម្រូវការត្រូវរៀបចំឱ្យច្បាស់លាស់ និងកំណត់ចំនួនជាក់លាក់ ដោយផ្តោតលើតម្រូវការណា ដែលគណៈកម្មការ និងសមាជិកសហគមន៍នេសាទអាចដោះស្រាយបាន។

ការចាត់អាទិភាពតម្រូវការដែលទាក់ទងនឹងបញ្ហា និងការគំរាមកំហែង៖

បន្ទាប់ពីកំណត់តម្រូវការរួច គឺត្រូវចាត់អាទិភាព។ នៅពេលចាត់អាទិភាព ត្រូវរកតម្រូវការសំខាន់ ដែលចាំបាច់ ចម្បង និងបន្ទាន់ជាងគេ និងជ្រើសរើសជាបន្តបន្ទាប់ តាមលំដាប់លំដោយ ដើម្បីឱ្យសហគមន៍នេសាទឆ្លើយតបនឹងតម្រូវការ និងទទួលបានលទ្ធផលល្អ។



### ៦.២.១.៤ កំណត់គោលដៅសម្រាប់ផែនការគ្រប់គ្រង

**គោលដៅ** គឺជាស្ថានភាពដែលអ្នកពាក់ព័ន្ធរួមគ្នាដើម្បីសម្រេចនូវអ្វីដែលចង់បាន។

ឧទា.៖ គោលដៅមួយ ឬច្រើនត្រូវបានរៀបចំឱ្យមានទំនាក់ទំនងជាមួយបញ្ហា និងការគំរាមកំហែងដែលបានរកឃើញ ហើយគោលដៅត្រូវរៀបចំឱ្យស្របតាមសមាសភាគទាំង៣ ដើម្បីសម្រេចនូវអ្វីដែលចង់បាន។ ១) គោលដៅផ្នែកបរិស្ថាន ២) គោលដៅផ្នែកសង្គម និង៣) គោលដៅផ្នែកអភិបាលកិច្ច។



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

គោលដៅគឺជាការពណ៌នាទូទៅអំពីស្ថានភាពដែលភាគីពាក់ព័ន្ធកំពុងអនុវត្តចង់បាន។ គោលដៅល្អឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ទស្សនៈវិស័យ៖ ការបំផុសគំនិតក្នុងការបញ្ជាក់ពីអ្វីដែលអ្នកពាក់ព័ន្ធកំពុងអនុវត្តចង់បាន
- បរិបទទូទៅ៖ ត្រូវបានកំណត់យ៉ាងទូលំទូលាយដោយរួមបញ្ចូលសកម្មភាពទាំងអស់
- សេចក្តីសង្ខេប៖ ងាយៗ និងសង្ខេប ដូចនេះភាគីពាក់ព័ន្ធងាយចងចាំ
- អាចវាស់វែងបាន៖ ត្រូវបានកំណត់ ដូចនេះការផ្លាស់ប្តូរអាចត្រូវបានវាយតម្លៃបានត្រឹមត្រូវ

គោលដៅមួយងាយស្រួលកំណត់ និងវាយតម្លៃបានត្រឹមត្រូវ លើការផ្លាស់ប្តូរជាងគោលដៅច្រើន។ ឧទា. គោលដៅច្រើនដូចជា៖

- ជលផល និងធនធានវារីសត្វដទៃទៀតត្រូវបានស្តារឡើងវិញ និងត្រូវបានគ្រប់គ្រងប្រកបដោយនិរន្តរភាព
- ជម្រក ដែលងាយរងគ្រោះ ថយចុះ និងសំខាន់ ត្រូវបានស្តារឡើងវិញ អភិរក្ស និងថែរក្សា

ឧទា.

គោលដៅ៖ ធ្វើឱ្យត្រីកើនឡើងវិញ និងកាត់បន្ថយការពឹងអាស្រ័យតែលើជលផលមួយមុខ។

- គោលដៅផ្នែកបរិស្ថាន៖ ធ្វើឱ្យបរិស្ថានប្រសើរឡើងវិញ
- គោលដៅផ្នែកសង្គម៖ រកចំណូលពីប្រភពផ្សេងៗទៀត ក្រៅពីនេសាទ
- គោលដៅផ្នែកអភិបាលកិច្ច៖ ស្វែងរកជំនួយពីខាងក្រៅ (អាចមានរដ្ឋបាលជលផល និងអង្គការមិនមែនរដ្ឋាភិបាលនានា)។

## ៦.២.២ ការបង្កើតផែនការគ្រប់គ្រង

### ៦.២.២.១ កំណត់គោលបំណង

**គោលបំណង**ត្រូវបានរៀបចំឡើង យោងទៅតាមបញ្ហា និងគោលដៅ បើសិនជាគេកំណត់បាន បញ្ហាជាក់លាក់ នោះវាមានភាពងាយស្រួលក្នុងការបង្កើតគោលបំណង។ គេត្រូវរៀបរាប់អំពីអ្វីដែលត្រូវធ្វើឱ្យសម្រេច។ ឧទា. ខាងក្រោមនេះបង្ហាញពីមែកធាងនៃគោលបំណង។



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

គោលបំណង ត្រូវបានបង្កើតឡើងដោយផ្អែកលើការគំរាមកំហែង បញ្ហា និងតម្រូវការ ដែលប៉ះពាល់ដល់គោលដៅ។ ប្រសិនបើការគំរាមកំហែង បញ្ហា ឬតម្រូវការត្រូវបានកំណត់យ៉ាងច្បាស់នោះ មិនលំបាកក្នុងការបង្កើតគោលបំណងឡើយ។ ប្រការនេះត្រូវការបញ្ជាក់ពីអ្វីដែលនឹងត្រូវបានសម្រេចជាទូទៅ។ ឧទា. កាត់បន្ថយផលប៉ះពាល់លើសត្វផ្សោត។

វិធីសរសេរគោលបំណងមានមានលក្ខណៈ ស្មាត ‘SMART’ (Hindson et al., 2005)៖

| | |
|---|---|
| Specific | ច្បាស់លាស់ /ចំៗ |
| Measurable | អាចវាស់វែងបាន (លទ្ធផលធៀបនឹងសូចនាករ) |
| Agreed | ឯកភាពពីគ្រប់អ្នកពាក់ព័ន្ធភាគច្រើន |
| Realistic | ប្រាកដប្រជា (អាចអនុវត្តបាន និងធនធានគ្រប់គ្រាន់) |
| Time dependent | កំណត់ពេលវេលាជាក់លាក់សម្រាប់សកម្មភាពចម្បងៗ |

ជាឧទាហរណ៍ បើសិនគោលដៅជីវសាស្ត្រគឺ៖ "*កាត់បន្ថយនៃការនេសាទហួសកម្រិត ដើម្បីបង្កើនផលនេសាទបានច្រើនដែលមាននិរន្តរភាព*"។ ប៉ុន្តែគោលបំណងលក្ខណៈស្មាតគឺ៖ "*ដើម្បីបង្កើនបរិមាណ និងទិន្នផលនៃប្រភេទត្រីខ្មៅ យ៉ាងហោចណាស់ ៣០% ពីកម្រិតបច្ចុប្បន្ននៅត្រឹមឆ្នាំ ២០២០*"។

គោលបំណង គឺជាការពណ៌នាដែលរៀបរាប់លម្អិតអំពីលទ្ធផលចុងក្រោយ។ គោលបំណងនៃគម្រោងសម្រាប់ការអនុវត្តរបស់សហគមន៍នេសាទ ឆ្លើយតបទៅនឹងគោលដៅរួម និងដោះស្រាយបញ្ហាសំខាន់ៗដែលបានកំណត់ ព្រមទាំងចំណាត់ថ្នាក់អាទិភាពដោយសមាជិកសហគមន៍នេសាទ។ ឧទា. ប្រសិនបើដីល្បាប់នៅតាមដងទន្លេ ត្រូវបានកំណត់ថាជាការគំរាមកំហែងខ្ពស់ចំពោះជម្រក និងស្តុកត្រី គោលបំណងដ៏សមស្របគឺ "ដើម្បីកាត់បន្ថយល្បាប់ក្នុងទន្លេ"។ ជាទូទៅ គោលបំណង អាចសម្រេចបាន ក្នុងក្របខណ្ឌធនធានគ្រប់គ្រាន់ និងរយៈពេលកំណត់។ គោលបំណង ជាមូលដ្ឋានសម្រាប់កំណត់សកម្មភាពគ្រប់គ្រងដែលត្រូវការ និងការសម្រេចចិត្តលើមធ្យោបាយវាស់វែងពីវឌ្ឍនភាពឆ្ពោះដែលសម្រេចបាននូវគោលដៅ។

## ៦.២.៣ ការអនុវត្តផែនការគ្រប់គ្រង

### ៦.២.៣.១ ការកំណត់វិធានការគ្រប់គ្រង/សកម្មភាព

**វិធានការគ្រប់គ្រង** ជាវិធានការចាំបាច់នានា ដើម្បីសម្រេចគោលបំណង ។ វិធានការគ្រប់គ្រង រួមបញ្ចូលទាំងទិដ្ឋភាពបច្ចេកទេស ដូចជា៖ ការកំណត់ចំពោះប្រភេទឧបករណ៍នេសាទហាមឃាត់ ការពង្រឹងវដ្តបិទនេសាទការពារវដ្តពងកូន។




*សម្រាប់វិធានការនីមួយៗ*ត្រូវបង្កើតគម្រោងដើម្បីកំណត់៖

- លទ្ធផលរំពឹងទុក (បង្កើតអ្វី ឬមានអ្វីដែលផ្លាស់ប្តូរ)
- ពេលវេលា (តើយុទ្ធសាស្ត្រ ត្រូវបានអនុវត្តក្នុងអំឡុងពេលណា?)
- អ្នកអនុវត្តសកម្មភាព (តម្រូវការកិច្ចសហប្រតិបត្តិការ ក្នុងការអនុវត្តសកម្មភាព)
- អ្នកទទួលខុសត្រូវឬស្ថាប័នអនុវត្តសកម្មភាព (អ្នកទទួលខុសត្រូវ ចំពោះការអនុវត្ត)
- តម្រូវការ និងប្រភពហិរញ្ញវត្ថុ។

### គន្លឹះសម្រាប់អ្នកសម្របសម្រួល

គោលបំណងនីមួយៗ ត្រូវការរៀបចំជម្រើសនៃវិធានការគ្រប់គ្រងផ្សេងៗ ដែលងាយស្រួលអនុវត្ត ងាយទទួលបានជោគជ័យ និងមានលទ្ធភាពធនធានហិរញ្ញវត្ថុគ្រប់គ្រាន់។

ការរួមបញ្ចូលគ្នានៃខ្លឹមសារខាងលើមានន័យថា ជាយុទ្ធសាស្ត្រនៃការគ្រប់គ្រង។

យុទ្ធសាស្ត្រគ្រប់គ្រង គួរតែចៀសវាង ឬបន្ថយផលប៉ះពាល់អវិជ្ជមាន លើសមាជិកសហគមន៍នេសាទរួមទាំងក្រុមដើមជនជាតិភាគតិច។ ក្នុងហេតុផលមួយចំនួន ប្រសិនបើយុទ្ធសាស្ត្រគ្រប់គ្រងមានការប៉ះពាល់ដល់ការចូលក្នុងតំបន់ហាមឃាត់ គេនឹងអនុវត្តតាមមាត្រាមួយចំនួនដែលបានពិពណ៌នានៅក្នុងក្របខ័ណ្ឌគោលនយោបាយតាំងទីលំនៅ។

## ៦.២.៣.២ ការគោរពច្បាប់ និងពង្រឹងការអនុវត្តច្បាប់

**អន្តរាគមន៍ពង្រឹងការអនុវត្តច្បាប់** អាចជាវិធានការទន់ភ្លន់ ឬដាក់ទណ្ឌកម្មធ្ងន់ធ្ងរ។

វិធានការទន់ភ្លន់ ជំរុញការអនុវត្តច្បាប់ដោយស្ម័គ្រចិត្ត យោងតាមលិខិតបទដ្ឋានគតិយុត្ត។ វិធីសាស្ត្របែបវិជ្ជមាននេះរួមមាន៖

- ការបំផុសចលនាក្នុងសង្គម
- ជំរុញបន្តប្រតិបត្តិការអនុវត្តល្អៗ
- ចែករំលែកព័ត៌មាន អប់រំ និងការចុះដល់មូលដ្ឋាន។

វិធានការក្តៅ អនុវត្តតាមច្បាប់ជាធរមាន។ វិធានការក្តៅ ឬអវិជ្ជមានរួមមាន៖

- វត្តមាននៃក្រុមអនុវត្តច្បាប់
- សកម្មភាពស្វែងរកចាប់ខ្លួន ប្តឹងជនល្មើស និងដាក់ទណ្ឌកម្មស្របតាមកំហុសរបស់ខ្លួន
- បដិសេធផលប្រយោជន៍សេដ្ឋកិច្ច ដែលបានមកពីសកម្មភាពល្មើស។



## គន្លឹះសម្រាប់អ្នកសម្របសម្រួល

ការពង្រឹងការអនុវត្តច្បាប់អាចជាវិធានការបង្ការ "ទន់ភ្លន់" ឬការដាក់ទណ្ឌកម្ម "ធ្ងន់ធ្ងរ"។ ការអនុវត្តច្បាប់ទន់ភ្លន់ជំរុញឱ្យមានការអនុលោមតាមស្ម័គ្រចិត្តតាមលក្ខខណ្ឌនៃច្បាប់ដោយមិនចាំបាច់ទៅតុលាការ។ ការអនុវត្តច្បាប់ទន់ភ្លន់ ផ្តោតលើសក្តានុពលសង្គម និងវប្បធម៌នៃការអនុលោមទៅតាមដែលអាចត្រូវបានប្រើប្រាស់ដើម្បីៈ ក) គាំទ្រដល់ការគោរពច្បាប់ទូលំទូលាយ ខ) លើកទឹកចិត្តគោរពស្ម័គ្រចិត្ត និង គ) សម្រេចបានការបង្ការទូទៅ។

វិធានការទន់ភ្លន់រួមមានៈ

- ការផ្សព្វផ្សាយក្នុងសង្គម ដូចជាការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយទំនាក់ទំនងសាធារណៈ ការប្រាស្រ័យទាក់ទង ការចូលរួមពីបុគ្គលល្បី (តារាកំប្លែង អ្នកជំនាញ វាគ្មិនកិត្តិយស) និងការស្វែងរកការគាំទ្រមតិ
- ការប្រាស្រ័យទាក់ទងសង្គមដូចជាៈ សិក្ខាសាលា កិច្ចប្រជុំ ទស្សនកិច្ចសិក្សា ទស្សនកិច្ចផ្លាស់ប្តូរ បទពិសោធន៍ ការស្វែងរកការគាំទ្រមតិ វេទិកាសាធារណៈ ការសម្តែងរឿងខ្លីៗ គណៈកម្មការសហគមន៍នេសាទ ក្រុមល្បាត ក្រុមឃ្លាំមើល និងការបញ្ចូលក្នុងកម្មវិធីសិក្សាជាដើម។

វិធានការតឹងរ៉ឹង ដែលអនុវត្តដោយអាជ្ញាធរមានសមត្ថកិច្ច និងតុលាការ ដើម្បីឱ្យមនុស្សរាងចាល។ វិធានការនេះមានគោលបំណង ដើម្បីកំណត់ជនល្មើស កំណត់ទីតាំង និងបង្ក្រាបជនល្មើសដោយប្រើប្រាស់គ្រប់រូបភាពនៃទិដ្ឋភាពច្បាប់ ។

វិធានការក្តៅរួមមាន៖

- ការពង្រឹងការអនុវត្តច្បាប់ជាបន្តបន្ទាប់ ដូចជាការល្បាតជាដើម
- សកម្មភាពស្វែងរកជាប្រចាំ ចាប់ជនល្មើស បញ្ជូនទៅតុលាការ និងដាក់ទណ្ឌកម្មតាមបទល្មើសជាក់ស្តែង
- មានយុទ្ធសាស្ត្រផ្សេងៗដែលប្រសើរសម្រាប់ដេញចាប់ជនល្មើសដែលមិនរាងចាលតាមរយៈ ក្រុមល្បាត ឬទូកប្រដេញ ប្រព័ន្ធត្រួតពិនិត្យ
- ធ្វើការរឹបអូសសម្ភារ ឧបករណ៍នេសាទពាក់ព័ន្ធនឹងសកម្មភាពនេសាទល្មើសច្បាប់។

## ៧. ការធ្វើបច្ចុប្បន្នភាពផែនការគ្រប់គ្រង

ជារៀងរាល់ឆ្នាំ សហគមន៍នេសាទត្រូវរៀបចំមហាសន្និបាតប្រចាំឆ្នាំ ដើម្បីពិនិត្យឡើងវិញនូវផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។ ការពិនិត្យឡើងវិញនេះ អនុវត្តតាមនីតិវិធីខាងលើ និងពិចារណាលើបញ្ហាជាអាទិភាព គោលដៅ និងសកម្មភាព។ ហិរញ្ញវត្ថុ និងប្រភពក៏ត្រូវពិនិត្យផងដែរ។

ការគ្រប់គ្រងសហគមន៍នេសាទ គឺជាដំណើរការ ដើម្បីសម្រេចគោលបំណងនានា។ ការតាមដានត្រួតពិនិត្យ ត្រូវធ្វើឡើងដើម្បីកំណត់ថាតើសកម្មភាពបានអនុវត្តតាមការគ្រោងទុកដែរឬទេ? ហើយការវាយតម្លៃ ត្រូវធ្វើឡើង ដើម្បីកំណត់ថាតើ អ្វីខ្លះជាមេរៀន និងបទពិសោធន៍ ពីជោគជ័យ និងបរាជ័យ។

ការវាយតម្លៃរួមមានការពិនិត្យឡើងវិញ និងប៉ាន់ប្រមាណនូវលទ្ធផល ដែលអនុវត្តបាន ដើម្បីជួយសម្រួល និងកែលម្អ តាមរយៈការរៀនសូត្រ (ការគ្រប់គ្រងដោយមានភាពបត់បែន)។



## ៨. ប្រភពថវិកា

ភាពគ្រប់គ្រាន់ ភាពទាន់ពេលវេលា ធនធានហិរញ្ញវត្ថុមាននិរន្តរភាពជាកត្តាគន្លឹះ ក្នុងការគាំទ្រដល់ការអនុវត្ត ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។ ធនធានហិរញ្ញវត្ថុមាននិរន្តរភាពគួរត្រូវបានគិតគូរតាំងពីដំបូងនៃផែនការ។

សហគមន៍នេសាទតម្រូវឱ្យមានប្រភពធនធានហិរញ្ញវត្ថុ។ ផែនការថវិកាត្រូវផ្អែកលើ ការវាយតម្លៃស្តីពីប្រតិបត្តិការ។

យោងតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ សហគមន៍អាចរកចំណូលពីប្រភពណាមួយ ឬគ្រប់គ្រងថវិកាដោយខ្លួនឯង។

ប្រភពធនធានហិរញ្ញវត្ថុមាននិរន្តរភាព រួមមាន៖

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល
- ចំណូលពីទេសចរណ៍ (សំបុត្រចូលទស្សនា និងជិះទូកកំសាន្ត ... )
- ចំណូលស្របច្បាប់ផ្សេងទៀត។

**គន្លឹះសម្រាប់អ្នកសម្របសម្រួល**

ធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ទាន់ពេលវេលា និងយូរអង្វែងដើម្បីគាំទ្រដល់ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ គឺមានសារៈសំខាន់ណាស់ ដើម្បីសម្រេចបាននូវនិរន្តរភាពយូរអង្វែងនៃសន្តិសុខស្បៀង ការចិញ្ចឹមជីវិត និងការអភិរក្ស ប្រព័ន្ធអេកូឡូស៊ីទឹក និងជីវចម្រុះ។ ហិរញ្ញវត្ថុត្រូវមានដើម្បីគាំទ្រដល់ប្រតិបត្តិការ និងមធ្យោបាយនានាដែលទាក់ទងនឹងការកសាងផែនការ ការអនុវត្តផែនការ ការសម្របសម្រួល ការត្រួតពិនិត្យ និងការពង្រឹងការអនុវត្តច្បាប់។ តាំងពីដំបូង សហគមន៍នេសាទត្រូវមានគំនិត និងផែនការ សម្រាប់ធានាធនធានហិរញ្ញវត្ថុឱ្យមាននិរន្តរភាព។

ការពឹងពាក់លើប្រភពធនធានពីខាងក្រៅច្រើនពេក នឹងមានផលប៉ះពាល់ ដល់និរន្តរភាព។ ប្រភពហិរញ្ញវត្ថុមួយចំនួន អាចត្រូវការជាចាំបាច់។ យន្តការធានាធនធានហិរញ្ញវត្ថុឱ្យមាននិរន្តរភាពត្រូវបានពិចារណា និងវាយតម្លៃជាផ្នែកសំខាន់នៃផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ដែលស្រដៀងទៅនឹងយុទ្ធសាស្ត្រថវិកាក្នុងផែនការអាជីវកម្ម។ ផែនការថវិកា ត្រូវផ្អែកលើការវាយតម្លៃនៃការចំណាយប្រតិបត្តិការសម្រាប់សកម្មភាពនានានៅក្នុងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ក្នុងរយៈពេលខ្លី និងរយៈពេលវែង។

យោងតាមអនុក្រឹត្យស្ដីពីការគ្រប់គ្រងសហគមន៍នេសាទនេះ សហគមន៍នេសាទ អាចរកប្រាក់ចំណូល និងគ្រប់គ្រងដោយខ្លួនឯង។ វាជាចំណូលស្របច្បាប់ដូចជាការចូលរួមវិភាគទានរបស់សមាជិកសហគមន៍នេសាទ អំណោយពីសប្បុរសជន និងចំណូលស្របច្បាប់ផ្សេងៗទៀត (មាត្រា ៣០)។ គណៈកម្មការសហគមន៍នេសាទ អាចបើកគណនី និងគ្រប់គ្រងហិរញ្ញវត្ថុសហគមន៍នេសាទតាមរបៀបតម្លាភាព និងការទទួលខុសត្រូវ (មាត្រា ២០)។

## សារតារ

គម្រោង "ការគ្រប់គ្រងធនធានទឹកចម្រុះទន្លេមេគង្គ - ដំណាក់កាលទី៣" ទទួលបានមូលនិធិពីធនាគារពិភពលោក។ គោលបំណងគម្រោង គឺដើម្បីបង្កើតមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងធនធានទឹក និងការគ្រប់គ្រងធនធានជលផលប្រកបដោយប្រសិទ្ធភាព នៅភាគឦសាននៃប្រទេសកម្ពុជា។ សមាសភាគទី ១ (ការគ្រប់គ្រងធនធានជលផលនៅភាគឦសាននៃប្រទេសកម្ពុជា) គ្រប់គ្រងដោយរដ្ឋបាលជលផល និងអនុវត្តដោយវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប។ គោលបំណងនៃសមាសភាគទី១គឺដើម្បីកែលម្អការគ្រប់គ្រងធនធានជលផលនៅក្នុងតំបន់គោលដៅដែលបានជ្រើសរើសនៅក្នុងខេត្តក្រចេះ និងស្ទឹងត្រែង។


## សៀវភៅមេរៀនចំនួន៥ ស្តីពីសហគ្រប់គ្រងធនធានជលផល

សៀវភៅមេរៀននេះគឺជាផ្នែកមួយនៃសៀវភៅមេរៀនជាស៊េរីចំនួន៥ ស្តីពីសហគ្រប់គ្រងជលផលនៅកម្ពុជា។ សៀវភៅមេរៀនទាំងនេះ សម្រាប់ភូមិដែលមានបំណងចង់បង្កើតសហគមន៍នេសាទ សមាជិកសហគមន៍នេសាទ សមាជិកគណៈកម្មការសហគមន៍នេសាទ និងមន្ត្រីខណ្ឌរដ្ឋបាលជលផល។

*សៀវភៅទី១: ការបង្កើតសហគមន៍នេសាទសហគមន៍*
*ក្រុមគោលដៅ: អ្នកភូមិ*
***សៀវភៅទី២: ការពង្រឹងសហគមន៍នេសាទ***
*ក្រុមគោលដៅ: សមាជិកសហគមន៍នេសាទ*
*សៀវភៅទី៣: ការពង្រឹងគណៈកម្មការសហគមន៍នេសាទ*
*ក្រុមគោលដៅ: សមាជិកគណៈកម្មាការសហគមន៍នេសាទ*
*សៀវភៅទី៤: ការពង្រឹងសមត្ថភាពខណ្ឌរដ្ឋបាលជលផល*
*ក្រុមគោលដៅ: បុគ្គលិករដ្ឋបាលជលផល*
*សៀវភៅទី៥: ការកសាងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍*
*ក្រុមគោលដៅ: សមាជិកសហគមន៍នេសាទ*
*ជាពិសេសសមាជិកគណៈកម្មាការសហគមន៍នេសាទ*


រដ្ឋបាលជលផល
វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ជលផលទឹកសាប
អាគារលេខ១៨៦ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ប្រទេសកម្ពុជា
គេហទំព័រ ifredi-cambodia.org

9 789924 927839